ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ១៥៥
ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦
សំណុំរឿងជំនុំជម្រះលេខ ៤០២
ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦
សាលក្រមលេខ ៣៨ (៣)
ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការលេខ ០១ នៃសាលាដំបូងខេត្តសៀមរាប នាថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង ០២ និង ០០ នាទីរសៀល ដោយមានសមាសភាពជំនុំជម្រះដូចតទៅ ៖

### ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] មុខងារ:ជា ចៅក្រម

### តំណាងអយ្យការ

លោក [redacted] មុខងារ:ជា ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៥ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានជនជាប់ចោទរាយនាមដូចខាងក្រោម ៖

(១).ជនជាប់ចោទឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិបឹង ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] រ) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (រ) មានប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

ឃាត់ខ្លួននៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ ឃុំខ្លួនជាបណ្ដោះអាសន្ននៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦៩ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ ។

(២).ជនជាប់ចោទឈ្មោះ [redacted] ស្មិត ភេទប្រុស អាយុ២៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិបឹង ឃុំជ្រាវ ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (ស) ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ០២ឆ្នាំ ។ (ក្នុងឃុំ)

Scanned by CamScanner

ឃាត់ខ្លួននៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ ឃុំខ្លួនជាបណ្ដោះអាសន្ននៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៧០ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០១៦ ។

(៣).ជនជាប់ចោទឈ្មោះ [redacted] សារឿន ហៅ ដា ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរអ្នកម៉ាស្សា កើតនៅភូមិភ្នំក្រោម ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិភ្នំក្រោម សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលើរ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

ឃាត់ខ្លួននៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ ឃុំខ្លួនជាបណ្ដោះអាសន្ននៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៧១ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០១៦ ។

ជាប់ចោទពីបទ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្ត នៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជម្រះលេខ ២៥៣៦ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប ។

**<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**

កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង០៤ និង៣០នាទី ទាបភ្លឺ កម្លាំងប្រជាការពារភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប បានធ្វើការល្បាត នៅភូមិក៏ប្រទះឃើញមនុស្សចំនួន០៣នាក់ ទី១ឈ្មោះ [redacted] វិសាល ភេទប្រុស អាយុ២៧ឆ្នាំ ទី២ឈ្មោះ [redacted] ស្ថិត ភេទប្រុស អាយុ២៨ឆ្នាំ ទី៣ឈ្មោះ [redacted] សារឿន ភេទស្រី អាយុ១៧ឆ្នាំ ។ ដោយមានសង្ស័យពីកម្លាំងប្រជាការពារបានធ្វើការហៅមក សាកសួរហើយជនសង្ស័យបានឆ្លើយសារភាពថា ពួកខ្លួនបានប្រើប្រាស់នូវសារធាតុ ញៀន នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ពិតមែនដោយឈ្មោះ [redacted] ស្ថិត ជាអ្នកទៅ ទិញថ្នាំញៀនពីជនមិនស្គាល់អត្តសញ្ញាណ គឺទិញក្នុងតម្លៃ ៥ (ប្រាំ) ដុល្លារអាមេរិក ដើម្បីយកមកចែកគ្នាប្រើប្រាស់ ។ ក្រោយពីបានសាកសួររួចមកកម្លាំងប្រជាការពារ បានបញ្ជូនជនសង្ស័យទាំង៣នាក់ ទៅការិយាល័យស្រាវជ្រាវប្រឆាំងគ្រឿងញៀន នៃ ស្នងការនគរបាលខេត្តសៀមរាបតែម្ដង ។



Scanned by CamScanner

## នាពេលសវនាការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារមេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងត្រឹមត្រូវហើយ

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៥ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០១៦ មកជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] ស្ទិត ,ឈ្មោះ [redacted] វិសាល, និង ឈ្មោះ [redacted] សារឿន ពីបទ"ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៨២ កថាខណ្ឌទី១-២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ស្ទិត បានឆ្លើយថា ៖ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោងជិតបួនភ្លឺខ្លួនកំពុងដេកនិយាយគ្នាលេងជាមួយសង្សារឈ្មោះ [redacted] លោង នៅក្នុងខ្ទមបន្ទាប់ពីបានប្រើប្រាស់សារធាតុញៀនរួច។ ស្រាប់តែសន្តិសុខភូមិឃើញក៏ទូរស័ព្ទហៅនគរបាលប៉ុស្តិ៍ឲ្យនាំទៅសាកសួរ និងតេស្តទឹកនោម ខ្លួនក៏សារភាពថាពិតជាបានប្រើប្រាស់ថ្នាំញៀនពិតមែន ។ ចំណែកឈ្មោះ [redacted] វិសាល និងឈ្មោះ ដា ដែលកំពុងដេកអោបគ្នានៅកុម្ពដើមរំចេកក៏ត្រូវនគរបាលនាំមកប៉ុស្តិ៍ដែល ។ ខ្លួនបានទៅទិញថ្នាំញៀនពីមនុស្សខ្មើយម្នាក់នៅមុខបឹងកាឡូ រួចយកមកប្រើប្រាស់ជាមួយឈ្មោះ [redacted] សារឿន ហៅ ដា និងឈ្មោះ [redacted] វិសាល ចំណែកសង្សារខ្លួនមិនបានប្រើប្រាស់ជាមួយនោះទេ ។ ឧបករណ៍ប្រើប្រាស់គ្រឿងញៀនជារបស់ខ្លួនផ្ទាល់ ។ ឃើញថាជនជាប់ចោទបានសារភាពថាខ្លួនជាអ្នកទៅទិញថ្នាំញៀន ហើយក៏ជាអ្នកច្នៃឧបករណ៍ជក់ឲ្យឈ្មោះ [redacted] វិសាល និង [redacted] សារឿន បានប្រើប្រាស់គ្រឿនញៀនជាមួយខ្លួនមែន ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វិសាល បានឆ្លើយថា៖ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ពេលល្ងាចឈ្មោះ [redacted] ស្ទិត បានយកម៉ូតូរបស់ខ្លួនទៅទិញថ្នាំញៀន តែមិនដឹងថាឈ្មោះ ស្ទិត ទៅទិញពីនរណានោះទេ ។ រហូតដល់វេលាម៉ោង១២យប់ ទើបឈ្មោះ ស្ទិត មកវិញបានថ្នាំញៀនមួយកញ្ចប់តូចយកមកប្រើជុំ

គ្នាជាមួយឈ្មោ[redacted]សារឿន ឈ្មោះ ស្មិត និងខ្លួន ។ ចំណែកសង្សារឈ្មោះ ស្មិត មិនបានប្រើគ្រឿងញៀនជាមួយទេ ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនបានពីរលើក ហើយទាំងលើកនេះ ។ ខ្លួនមិនដែលជួញដូរ ឬចែកចាយគ្រឿងញៀនអ្វីទេ ។ ចំពោះឧបករណ៍ប្រើប្រាស់គ្រឿងញៀនជារបស់ឈ្មោះ ស្មិត ។ ចំណែកគ្រឿងញៀនឈ្មោះ ស្មិត និងខ្លួនបានចូលលុយគ្នាម្នាក់មួយម៉ឺនរៀល ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោ[redacted]សារឿន បានឆ្លើយថា ៖ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោងប្រហែលដប់មួយយប់ខ្លួន និងមនុស្សស្រីម្នាក់ទៀតដែលមិនស្គាល់ឈ្មោះកំពុងដើរតាមមាត់ស្ទឹងហើយបានជួបនឹងមនុស្សប្រុសពីរនាក់ដែលមិនស្គាល់ឈ្មោះមកបបួលទៅញ៉ាំមីឆា តែមិនបានញ៉ាំទេបែរជាបបួលទៅប្រើថ្នាំញៀននៅខ្ទមស្រែផ្លូវក្រវ៉ាត់ក្រុងភូមិក្រសាំង សង្កាត់ជ្រាវ ។ នៅពេលនោះមានគ្នាបួននាក់ស្រីពីរប្រុសពីរ តែការប្រើប្រាស់គ្រឿងញៀនប្រើតែគ្នាបីនាក់ទេគឺឈ្មោះ[redacted]វិសាល ឈ្មោះ ប្លង់ ស្មិត និងខ្លួន ។ ចំណែកស្រីម្នាក់ទៀតមិនបានប្រើនោះទេ ។ ខ្លួនទើបតែប្រើប្រាស់គ្រឿងញៀនលើកទី១ ហើយក៏មិនដែលជួញដូរ ឬចែកចាយគ្រឿងញៀនអ្វីដែរ ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ស្មិត , ឈ្មោះ [redacted] វិសាល និងឈ្មោ[redacted]សារឿន នាំឲ្យតុលាការជឿបានថាជនជាប់ចោទឈ្មោះ ប្លង់ ស្មិត ពិតជាបានចាត់ចែងឲ្យឈ្មោះ [redacted]វិសាល និងឈ្មោ[redacted] សារឿន ប្រើប្រាស់គ្រឿងញៀនជាមួយខ្លួនពិតប្រាកដមែន ។ អំពើរបស់ឈ្មោះ[redacted] ស្មិត ជាបទល្មើស"ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ កថាខណ្ឌទី១-២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] វិសាល និងជនជាប់ចោទឈ្មោះ [redacted] សារឿន ប្រព្រឹត្តអំពើត្រឹមតែប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះ ។

-អំពើរបស់ជនជាប់ចោទឈ្មោ[redacted]ស្មិត បានបំពេញធាតុផ្សំនៃបទល្មើស "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ កថាខណ្ឌទី១-២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ចំណែកអំពើរបស់ជនជាប់ចោទឈ្មោ[redacted] វិសាល និងជនជាប់ចោទឈ្មោះ[redacted] សារឿន បានបំពេញធាតុផ្សំនៃបទល្មើស "ប្រើប្រាស់ដោយ



Scanned by CamScanner

ខុសច្បាប់នូវសារធាតុញៀន" បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-ជនជាប់ចោទឈ្មោះ [redacted] ស្វិត និងឈ្មោះ [redacted]វិសាល សុទ្ធតែជានីតិជនមានស្មារតីល្អគ្រប់គ្រាន់អាចពិចារណាដឹងបានពីផលវិបាកដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត និងមានបុគ្គលិកលក្ខណៈសម្បត្តិពេញលេញក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌបាន ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] សារឿន ភេទស្រី អាយុ១៧ឆ្នាំ គឺជាអនីតិជន តែមានបុគ្គលិកលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌបាន ។ ដោយជនជាប់ចោទឈ្មោះ [redacted] សារឿន ជាអនីតិជន ហេតុនេះតុលាការនឹងពិចារណាទោសអនុវត្តចំពោះជនជាប់ចោទតាមបញ្ញត្តិមាត្រា១៦០ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស្វិត ពីបទ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ កថាខណ្ឌទី១-២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ព្រមទាំងជនជាប់ចោទឈ្មោះ[redacted]សាល និងឈ្មោះ [redacted] សារឿន ពីបទ "ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

- វត្ថុតាងដែលជាសម្ភារៈសម្រាប់ប្រើប្រាស់គ្រឿងញៀន គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល ។ ចំណែកម៉ូតូ HONDA DREAM C125 ពណ៌ខ្មៅផលិតឆ្នាំ ២០០៥ លេខតួលេខម៉ាស៊ីន ND125ME-8072046 ពាក់ស្លាកលេខសៀមរាប 1E-2902 មិនមែនពាក់ព័ន្ធនឹងបទល្មើស គប្បីសម្រេចប្រគល់ឲ្យទៅម្ចាស់ដើមវិញ ។

- មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted] សារឿន បានសន្និដ្ឋានការពារថា កូនក្តីខ្លួនឈ្មោះ [redacted] សារឿន ជាអនីតិជន ហើយជាជនរងគ្រោះនៃការប្រើប្រាស់គ្រឿនតែប៉ុណ្ណោះ ។ ហេតុនេះសុំឲ្យតុលាការផ្តន្ទាទោសកូនក្តីពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងសុំឲ្យតុលាការផ្តន្ទាទោសតាមបញ្ញត្តិស្តីពីទោសសម្រាប់អនីតិជន ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំតម្កល់ការចោទប្រកាន់ និងសុំឲ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់ ។

# ហេតុដូច្នេះសម្រេច

I-ផ្តន្ទាទោស ៖

ក-ឈ្មោះ [redacted] ស្មិត ភេទប្រុស កើតឆ្នាំ១៩៩២ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ពីបទ "ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ កថាខណ្ឌទី១-២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ-ឈ្មោះ [redacted] វិសាល ភេទប្រុស កើតឆ្នាំ១៩៨៩ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ ។

គ-ឈ្មោះ [redacted] សារឿន ហៅ ដា ភេទស្រី កើតឆ្នាំ១៩៩៩ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ខែ ។

ពីបទ "ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

II- វត្ថុតាងដែលជាសម្ភារៈសម្រាប់ប្រើប្រាស់គ្រឿងញៀន ត្រូវសម្រេចរឹបអូសបំផ្លាញចោល ។ ចំណែកម៉ូតូម៉ាក HONDA DREAM C125 ពណ៌ខ្មៅផលិតឆ្នាំ២០០៥ លេខតួលេខម៉ាស៊ីន ND125ME-8072046 ពាក់ស្លាកលេខសៀមរាប 1E-2902 ត្រូវសម្រេចប្រគល់ឲ្យទៅម្ចាស់ដើមវិញ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្មិត ,ឈ្មោ [redacted] វិសាល និងឈ្មោះ [redacted] សារឿន ហៅ ដា ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខានិងត្រា

[redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខានិងត្រា

[redacted]

**បានឃើញ**

សៀមរាប, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦

**ចៅក្រមជំនុំជម្រះ**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

សៀមរាប, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦

**ក្រឡាបញ្ជី**

[redacted]

Scanned by CamScanner